00578841

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

លេខ/No: D193/5/5

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៥៧)**

**ចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នីយ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០

---

**សាធារណៈ**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
**ចំពោះដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរ**
**ទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនត្រូវចោទ**
អៀង ធីរិទ្ធ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04/08/2010
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 04/08/2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

នី ច័ន្ទឌី

ឡៅ ជុនធី

Silke STUDZINSKY

គង់ ពិសី

ហុង គីមសួន

យុង ផានិត

ស៊ីន សុវ៉ន

**ចូលរួមប្ដឹងដោយ**

Mahdev MOHAN
Fabienne TRUSSES-NAPROUS
Laura DESFORGES
Christine MARTINEAU
Isabelle DURAND
Françoise GAUTRY

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

Martine JACQUIN
Philippe CANONNE
Fabienne TRUSSES-NAPROUS
Elizabeth-Joelle RABESANRATANA
Annie DELAHAIE

**ជំនួយការឡាប់**

Katrina GORDON

**សហមេធាវីការពារក្ដីជនត្រូវចោទ**

ផាត់ ពៅស៊ាង

Diana ELLIS

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ជេត វណ្ណលី

ពេជ អង្គ

Olivier BAHOUGNE
Lyma NGUYEN
Marie GUIRAUD
Partirck BAUDOUIN

**ដើមបណ្ដឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាង**

00578843



**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (**"អ.វ.ត.ក"**) បានទទួលបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះដីកាសម្រេចរបស់[សហចៅក្រមស៊ើបអង្កេត]លើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ដែលបានដាក់ប្តឹងនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១០ ("បណ្តឹងឧទ្ធរណ៍")[១]។

## I. **ប្រវត្តិនីតិវិធី**

១. នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("ម្ចាស់បណ្តឹងឧទ្ធរណ៍") បានដាក់សំណើសុំលើកទី៣របស់សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំបំពេញកិច្ចស៊ើបសួរទៅលើទ្រព្យសម្បត្តិទាំងអស់របស់ជនត្រូវចោទ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ("សំណើសុំ")[២]។ យោងតាមសំណើនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យៈ (i) បើកកិច្ចស៊ើបសួរឱ្យបានពេញលេញទៅលើទ្រព្យសម្បត្តិរបស់ជនត្រូវចោទ ហើយដាក់លទ្ធផលនៃការស៊ើបអង្កេតទាំងអស់ចូលទៅក្នុងសំណុំរឿង (ii) ចាត់វិធានការនានាដើម្បីរក្សាទ្រព្យសម្បត្តិរបស់ជនត្រូវចោទទុកសម្រាប់សងសំណង និង (iii) កំណត់អត្តសញ្ញាណនូវទ្រព្យសម្បត្តិដែលត្រូវបានផ្ទេរពីជនត្រូវចោទទៅសមាជិកគ្រួសាររបស់គេ ដើម្បីបញ្ជាក់អំពីប្រភពនៃទ្រព្យសម្បត្តិ ថាតើទ្រព្យសម្បត្តិទាំងនោះ បានមកដោយសារតួនាទីរបស់ជនត្រូវចោទនៅក្នុងរបបខ្មែរក្រហមដែរឬទេ[៣]។ អង្គបុរេជំនុំជម្រះមានបំណងកត់សម្គាល់ដោយសង្ខេបថា សារណានានាពីសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយតបផ្សេងៗទៅនឹងសារណាទាំងនោះ រួមទាំងការដាក់ឯកសារនានា គឺត្រូវចាត់ជា "សម្ងាត់"។ អង្គបុរេជំនុំជម្រះគិតដល់ "តម្រូវការទាមទារ

---

[១] បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១០ D193/5/1 ("បណ្តឹងឧទ្ធរណ៍")។

[២] សំណើលើកទី៣របស់សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំបំពេញកិច្ចស៊ើបសួរទៅលើទ្រព្យសម្បត្តិទាំងអស់របស់ជនត្រូវចោទ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ឯកសារ D193 ("សំណើ")។

[៣] សំណើ កថាខណ្ឌ២៥។



អង្គបុរេជំនុំជម្រះ E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ឲ្យមានតុល្យភាពរវាងការសម្ងាត់នៃការស៊ើបសួររបស់តុលាការ និងផ្នែកផ្សេងៗទៀតនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការដែលមិនបើកចំហដល់សាធារណជន តម្រូវការដើម្បីធានាដល់តម្លាភាពនៃកិច្ចដំណើការនីតិវិធីសាធារណៈ និងសម្រាប់គោលបំណងនៃការអប់រំ និងកេរ្តិ៍ដំណែល"[៤]។ អង្គបុរេជំនុំជម្រះបានធ្វើការពិនិត្យលើសារណា និងចម្លើយតបនានាពីភាគី រួមទាំងសេចក្តីដកស្រង់ផ្សេងៗដែលត្រូវសរសេរឡើងវិញនៅក្នុងសាលដីកានេះ។ ដោយឈរលើគោលការណ៍គ្រឹះដែលបានកត់សម្គាល់ខាងលើ និងកត់សម្គាល់ជាពិសេសលើបញ្ហានានាដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះបានសម្រេចថា សាលដីកានេះត្រូវចាត់ជាសាធារណៈ ថ្វីបើភាគីបានស្នើសុំពីចំណាត់ថ្នាក់ក៏ដោយ។

២. នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៩ ក្រុមមេធាវីការពារក្តី អៀង សារី ("ក្រុមមេធាវីការពារក្តី អៀង សារី") បានដាក់ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើទីពីររបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យបំពេញកិច្ចស៊ើបសួរ ទាក់ទងនឹងទ្រព្យសម្បត្តិដែលគេចោទថាជាកម្មសិទ្ធិរបស់ជនត្រូវចោទ ("ចម្លើយតបរបស់ អៀង សារី") ដោយចម្លើយតបនេះជំទាស់នឹងសំណើសុំ[៥]។

៣. នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ ("ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ") បានដាក់ការជំទាស់របស់មេធាវីការពារក្តីទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីពីររបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរបស់ជនត្រូវចោទ ("ការជំទាស់របស់ អៀង ធីរិទ្ធ") ដោយការជំទាស់នេះបានជំទាស់នឹងសំណើសុំ[៦]។

---

[៤] សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង អវតក/០០៤/២០០៩ មាត្រា ១.២។

[៥] ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើទីពីររបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យបំពេញកិច្ចស៊ើបសួទាក់ទងនឹងទ្រព្យសម្បត្តិដែលគេចោទថាជាកម្មសិទ្ធិរបស់ជនត្រូវចោទ ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D193/2 ("ចម្លើយតបរបស់ អៀង សារី")។

[៦] ការជំទាស់របស់មេធាវីការពារក្តីទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីពីររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរបស់ជនត្រូវចោទ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D193/3 ("ការជំទាស់របស់ អៀង ធីរិទ្ធ")។



E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

៤. នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចបដិសេធសំណើសុំ ("ដីកាសម្រេចដែលត្រូវបានជំទាស់")[៧]។ សហចៅក្រមស៊ើបអង្កេតបានផ្តល់នូវមូលដ្ឋានដូចខាងក្រោមនៅពេលខ្លួនចេញដីកាសម្រេចដែលត្រូវបានជំទាស់នេះ ពោលគឺ៖ (i) សំណើសុំស្ថិតនៅក្រៅវិសាលភាពនៃការស៊ើបអង្កេត (ii) ចំណុចមួយចំនួននៅក្នុងសំណើសុំហួសពីសមត្ថភាពរបស់សហចៅក្រមស៊ើបអង្កេត ដែលតួនាទីរបស់ខ្លួនកម្រិតត្រឹមការស៊ើបអង្កេត (iii) យុត្តិសាស្ត្រអន្តរជាតិទាក់ទិននឹងការបង្កកទ្រព្យសម្បត្តិ បានកំណត់លក្ខខណ្ឌខ្ពស់ក្នុងការបំពេញកិច្ចស៊ើបសួរ ដូចដែលបានស្នើសុំតាមសំណើសុំ ហើយសហចៅក្រមស៊ើបអង្កេតមិនមានភស្តុតាងនៅចំពោះមុខខ្លួនដែលបានបង្ហាញថា ម្ចាស់បណ្តឹងឧទ្ធរណ៍បានបំពេញតាមលក្ខខណ្ឌខ្ពស់នេះឡើយ និង (iv) ផ្នែកគាំពារការការពារក្តីបានរកឃើញពីពេលមុនថា ជនត្រូវចោទជាអសាធនីយជន ហើយសហចៅក្រមស៊ើបអង្កេតមិនមានមូលដ្ឋានណាដើម្បីជំទាស់លើការសម្រេចបែបនេះឡើយ[៨]។

៥. នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០១០ ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចដែលត្រូវបានជំទាស់ ហើយនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១០ ដើមបណ្តឹងឧទ្ធរណ៍បានដាក់បណ្តឹងឧទ្ធរណ៍។ យើងកត់សម្គាល់ឃើញថា ក្រុមចំនួនបួនមិនមែនជាភាគីនៃសំណើសុំឡើយ ហេតុដូច្នេះ ដើម្បីអាចឱ្យចូលរួមនៅក្នុងបណ្តឹងឧទ្ធរណ៍នេះបាន ក្រុមទាំងបួននេះត្រូវបានដាក់បញ្ចូលជាមួយភាគី ដោយបញ្ជាក់ថាបាន "ចូលរួមប្តឹង"។ ដោយសារភាគីផ្សេងទៀតមិនបានជំទាស់នឹងករណីនេះ និងដោយសារក្រុមទាំងនេះចាប់អារម្មណ៍ចង់ចូលរួមនៅក្នុងបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យក្រុមទាំងនេះចូលរួមជាភាគីនៅក្នុងបណ្តឹងឧទ្ធរណ៍។

* អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

---

[៧] ដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១០ ឯកសារ D193/4 ("ដីកាដែលត្រូវបានជំទាស់")។

[៨] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ២-៨។

00578846



៦. ម្ចាស់បណ្ដឹងឧទ្ធរណ៍បានលើកឡើងថា ដីកាសម្រេចដែលត្រូវបានជំទាស់មានកំហុសអង្គច្បាប់ និងកំហុសអង្គហេតុដូចតទៅៈ (i) ដីកាសម្រេចដែលត្រូវបានជំទាស់ខកខានមិនបានធានា និងគោរពសិទ្ធិទាំងឡាយរបស់ជនរងគ្រោះ ដូចមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង[៩] និងលិខិតុបករណ៍អន្តរជាតិ (ii) សហចៅក្រមស៊ើបអង្កេតមានកំហុសនៅពេលសម្រេចថា សហចៅក្រមស៊ើបអង្កេតមិនមែនជាស្ថាប័នសមស្របក្នុងការអនុវត្តសំណាងនៅក្នុងដំណាក់កាលបឋមនេះឡើយ ហើយ (iii) ដីកាសម្រេចដែលត្រូវបានជំទាស់បានផ្អែកលើការសន្និដ្ឋានមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែតលើអង្គហេតុ ដោយសារម្ចាស់បណ្ដឹងឧទ្ធរណ៍យល់ឃើញថា (ក) មានភស្តុតាងបង្ហាញថា ជនត្រូវចោទទទួលផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និង (ខ) ដីកាសម្រេចដែលត្រូវបានជំទាស់បានផ្អែកលើការទាយស្មានរបស់សហចៅក្រមស៊ើបអង្កេត លើលទ្ធផលនៃការស៊ើបអង្កេតដែលកំពុងដំណើរការ[១០]។ យោងតាមបណ្ដឹងឧទ្ធរណ៍ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានស្នើសុំឱ្យអង្គបុរេជំនុំជម្រះច្រានចោលដីកាសម្រេចដែលត្រូវបានជំទាស់ ហើយបង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរដូចដែលបានស្នើសុំ[១១]។

៧. នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០ ក្រុមមេធាវីការពារក្ដី អៀង ធីរិទ្ធ បានដាក់ "ចម្លើយតបរបស់មេធាវីការពារក្ដីចំពោះបណ្ដឹងឧទ្ធរណ៍របស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន" ("ចម្លើយតបរបស់មេធាវីការពារក្ដី អៀង ធីរិទ្ធ")[១២]។ ក្រុមមេធាវីការពារក្ដី អៀង ធីរិទ្ធ បានសន្និដ្ឋានថា បណ្ដឹងឧទ្ធរណ៍គួរតែបដិសេធចោល ពីព្រោះ (i) សំណើសុំបានធ្វើឡើងនៅមុនដំណាក់កាលនីតិវិធី (ii) ច្បាប់ជាធរមានមិនបានចែងអំពីឯកត្តកម្មនៃសំណង (iii) កិច្ចស៊ើបសួរដែលស្នើសុំដោយម្ចាស់បណ្ដឹងឧទ្ធរណ៍

---

[៩] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៥) ដូចដែលត្រូវបានពិនិត្យឡើងវិញនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០។

[១០] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ១៤-៣០។

[១១] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ៣០។

[១២] ចម្លើយរបស់មេធាវីការពារក្ដីចំពោះបណ្ដឹងឧទ្ធរណ៍របស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ ដែលជនត្រូវចោទមាន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០ ឯកសារ D193/5/2 ("ចម្លើយតបរបស់ អៀង ធីរិទ្ធ")។

00578847



ស្ថិតនៅក្រៅវិសាលភាពនៃកិច្ចស៊ើបសួរ (iv) សហចៅក្រមស៊ើបអង្កេតមិនមែនជាស្ថាប័នសមស្របក្នុងការអនុវត្តសំណង និង (v) ដើមបណ្តឹងឧទ្ធរណ៍បានសន្និដ្ឋានដោយមិនត្រឹមត្រូវថា ការវាយតម្លៃលើភាពក្រីក្ររបស់ជនត្រូវចោទ មានលក្ខណៈស្រពិចស្រពិល ហើយមិនបានផ្តល់ភស្តុតាងបន្ថែមជាមូលដ្ឋានគាំទ្រដល់ការចោទប្រកាន់របស់ខ្លួនថា អៀងធីរិទ្ធ មានថវិកាច្រើនណាស់ ដែលលួចមកពីមូលនិធិរបស់អង្គការបដិវត្តន៍[១៣]។

៨. យោងតាមសេចក្តីសម្រេចចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១០[១៤] អង្គបុរេជំនុំជម្រះបានជូនដំណឹងដល់ភាគីនានាថា បណ្តឹងឧទ្ធរណ៍នឹងយកមកសម្រេចដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ អនុលោមតាមវិធាន ៧៧(៣)(ខ)នៃវិធានផ្ទៃក្នុង។

៩. នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានប្រកាសសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ដោយបានបញ្ជាក់ថា "សាលដីកាដែលមានសំអាងហេតុលើបណ្តឹងឧទ្ធរណ៍នេះនឹងប្រកាសចេញនៅក្នុងពេលសមស្របខាងមុខ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**មិនទទួលយកបណ្តឹងឧទ្ធរណ៍នេះ**"[១៥]។

## II. **ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍**

១០. ដីកាសម្រេចដែលត្រូវបានជំទាស់ត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០១០។ ដើមបណ្តឹងឧទ្ធរណ៍បានដាក់សេចក្តីជូនដំណឹងនៃបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចដែលត្រូវ

---

[១៣] ចម្លើយតបរបស់ អៀង ធីរិទ្ធ កថាខណ្ឌ៣-១៧។

[១៤] សេចក្តីសម្រេចដើម្បីកំណត់លើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងសេចក្តីណែនាំឲ្យដាក់ការឆ្លើយតប ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១០ ឯកសារ D193/5/3។

[១៥] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D193/5/4។



E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

បានជំទាស់នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០។ បណ្តឹងឧទ្ធរណ៍ត្រូវបានជូនដំណឹងនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១០ នៅក្នុងរយៈពេលកំណត់ដូចមានចែងនៅក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង។

**មូលដ្ឋាននៃការដាក់បណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧៤(៤) នៃវិធានផ្ទៃក្នុង**

១១. បណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់ប្តឹងតាមវិធាន ៧៤(៤)(ក)[១៦] នៃវិធានផ្ទៃក្នុង។ វិធាននេះ អនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍ ចំពោះដីការបស់សហចៅក្រមស៊ើបអង្កេតដែលបានសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរស្របតាមវិធានផ្ទៃក្នុង។

១២. សំណើសុំត្រូវបានដាក់ជូនអនុលោមតាមវិធាន ៥៥(១០) និងវិធាន ៥៩(៥)នៃវិធានផ្ទៃក្នុង[១៧]។ វិធាន ៥៥(១០)នៃវិធានផ្ទៃក្នុងចែងថា៖

> នៅគ្រប់ពេលវេលានៃការស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬ បំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រម សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធ ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយនៅគ្រប់ករណីទាំងអស់ត្រូវចេញដីកានេះឱ្យបានមុនពេលបញ្ចប់កិច្ចស៊ើបសួរ។ ដីកាបដិសេធនេះ ត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ភាគី។ ដីកាបដិសេធនេះបើកផ្លូវប្តឹងឧទ្ធរណ៍។

**វិធាន ៥៩(៥) នៃវិធានផ្ទៃក្នុងចែងថា៖**

> ក្នុងអំឡុងពេលស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី ចុះទៅដល់ទីកន្លែងកើតហេតុ បង្គាប់ឱ្យធ្វើកោសល្យវិច័យ ឬប្រមូលយកភស្តុតាងដទៃទៀត។ សំណើនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយមានមូលហេតុពិតប្រាកដ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រមតាមសំណើនេះទេ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន និងនៅគ្រប់ករណីទាំងអស់ ត្រូវចេញដីកាបដិសេធនៅមុនពេលបញ្ចប់ការស៊ើបសួរ។ ដីកាបដិសេធនេះ ត្រូវមាន

---

[១៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១១។

[១៧] សំណើ កថាខណ្ឌ១។

សំអាងហេតុ ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានជូនដំណឹងជាបន្ទាន់អំពីដីកាបដិសេធនេះ និងអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះទៅអង្គបុរេជំនុំជម្រះ ។

១៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដើមបណ្តឹងឧទ្ធរណ៍បានដាក់សំណើសុំអនុលោមតាមវិធាន ៥៥(១០) និងវិធាន ៥៩(៥) នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា សំណើសុំនេះគឺជាសំណើសុំដែលធ្វើឡើងអនុលោមតាមវិធាន ៥៥(១០)នៃវិធានផ្ទៃក្នុង ហេតុដូច្នេះ នៅក្នុងសាលដីកានេះ អង្គបុរេជំនុំជម្រះចាត់ទុកថាជាសំណើសុំអនុលោមតាមវិធាន ៥៥(១០)។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សេចក្តីពិចារណានៅចំពោះមុខអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នេះ នឹងមានលក្ខណៈដូចគ្នា ប្រសិនបើសំណើសុំត្រូវបានកំណត់លក្ខណៈសម្បត្តិថាជាសំណើសុំដែលធ្វើឡើងតាមវិធាន ៥៩(៥) នៃវិធានផ្ទៃក្នុង ឬជាសំណើសុំដែលធ្វើឡើងតាមវិធាន ៥៥(១០)នៃវិធានផ្ទៃក្នុង។

១៤. ទោះបីជាកិច្ចដែលបានស្នើសុំបានរៀបរាប់លម្អិតទៅតាមទម្រង់ក៏ដោយ ដើម្បីទទួលយកកិច្ចនេះបាន កិច្ចនេះត្រូវជាប់ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ ដែលបើកឱ្យបំពេញតាមវិធានផ្ទៃក្នុង។ សហចៅក្រមស៊ើបអង្កេតអាចទទួលយកសំណើសុំបំពេញកិច្ចស៊ើបសួរបាន ប្រសិនបើកម្មវត្ថុនៃសំណើស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបអង្កេត[១៨]។ វិសាលភាពនៃការស៊ើបអង្កេតនៅចំពោះមុខ អ.វ.ត.ក ត្រូវបានកំណត់ដោយដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា មិនថាដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឡើយ[១៩]។ នៅពេលពិចារណាលើសំណើនានាដែលបានធ្វើឡើងតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តតាមវិធាន ៥៥(២) នៃវិធានផ្ទៃក្នុង

---

[១៨] សូមមើល វិធាន៥៥(២) នៃវិធានផ្ទៃក្នុង និង សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេត ឯកសារ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកា D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ស្តីពីភាពអាចទទួលយកបាននៃសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ ឯកសារ D250/3/2/1/5 ("សាលដីកាទាក់ទងនឹងដីកាសម្រេចរួម")។ នៅក្នុងដីកា សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញថា ខ្លួនត្រូវបានចងកាតព្វកិច្ចដោយវិសាលភាពនៃកិច្ចស៊ើបសួរផ្លូវការ។ សូមមើល ដីកា កថាខណ្ឌ ៣ និងជើងទំព័រលេខ២ សម្រាប់ការរាយឈ្មោះសង្ខេបអំពីដីកានានាដែលចេញកាលពីលើកមុនរបស់សហចៅក្រមស៊ើបអង្កេតដែលផ្ទុះបញ្ជាំងដូចគ្នា។

[១៩] វិធាន៥៣ និង ៥៥(៣) នៃវិធានផ្ទៃក្នុង។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ដែលវិធាននេះដាក់លក្ខខណ្ឌឱ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរលើអង្គហេតុទាំងឡាយដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមតែប៉ុណ្ណោះ[២០]។ ប្រសិនបើសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងអង្គហេតុដែលស្ថិតនៅក្រៅវិសាលភាពនៃអង្គហេតុដូចបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម (អង្គហេតុនោះជា "អង្គហេតុថ្មី") សហចៅក្រមស៊ើបអង្កេតមិនមានអំណាចទទួលយកសំណើនេះឡើយ។ ប្រសិនបើសំណើដែលដាក់ជូនទៅសហចៅក្រមស៊ើបអង្កេតទាក់ទិននឹងអង្គហេតុថ្មី វិធាន ៥៥(៣)នៃវិធានផ្ទៃក្នុងតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់សហព្រះរាជអាជ្ញាអំពីអង្គហេតុថ្មីនោះ។ សហចៅក្រមស៊ើបអង្កេតមិនអាចស៊ើបអង្កេតបានឡើយ ដរាបណាសហព្រះរាជអាជ្ញាមិនបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងអង្គហេតុថ្មីនោះ។ វិធាន ៥៥(៣) និងវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងកម្រិតអំណាចរបស់សហចៅក្រមស៊ើបអង្កេតលើការទទួលសំណើ ដោយអនុញ្ញាតឱ្យទទួលយកបញ្ហាទាំងឡាយណាដែលស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបអង្កេត ដូចបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[២១]។

១៥. ដូចដែលបានបញ្ជាក់ពីមុនដោយអង្គបុរេជំនុំជម្រះរួចហើយ អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌកម្រិតដូចមានចែងនៅក្នុងវិធាន ៥៥(៣) នៃវិធានផ្ទៃក្នុងលើសហចៅក្រមស៊ើបអង្កេតអនុវត្តចំពោះសំណើទាំងឡាយ ដែលបានធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី

[២០] វិធាន៥៥(២) នៃវិធានផ្ទៃក្នុង។

[២១] វិធាន៥៥(៣) នៃវិធានផ្ទៃក្នុងចែងដូចខាងក្រោម៖

"ក្នុងអំឡុងពេលស៊ើបសួរ ប្រសិនបើមានលេចចេញអង្គហេតុថ្មី សហចៅក្រមស៊ើបអង្កេតត្រូវជូនព័ត៌មានដល់សហព្រះរាជអាជ្ញា លើកលែងតែអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសនៃអង្គហេតុដែលមានកំនត់ក្នុងដីកាសន្និដ្ឋានដែលមានស្រាប់។ កាលណាអង្គហេតុថ្មីនេះ ត្រូវបានបញ្ជូនទៅឱ្យសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតគ្មានអំណាចធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះបានឡើយ លុះត្រាតែទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីសហព្រះរាជអាជ្ញា"។

00578851



ដែរ[២២]។ នៅក្នុងសាលដីកាលើដីកាសម្រេចរួម អង្គបុរេជំនុំជម្រះបានសម្រេចថា ដើមបណ្តឹងរដ្ឋប្បវេណី "...អាចជម្រាបអង្គហេតុថ្មីជូន[សហចៅក្រមស៊ើបអង្កេត] ឬសហព្រះរាជអាជ្ញាបាន ប៉ុន្តែខ្លួនពុំមានសិទ្ធិស្នើសុំបំពេញកិច្ចលើអង្គហេតុថ្មីទាំងនេះឡើយ លើកលែងតែសហព្រះរាជអាជ្ញាបានបញ្ចូលអង្គហេតុទាំងនេះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម"[២៣]។ ដោយសារដើមបណ្តឹងរដ្ឋប្បវេណីមិនមានសិទ្ធិដូច្នេះ បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន[២៤]។

១៦. ម្ចាស់បណ្តឹងឧទ្ធរណ៍សន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបានដោយឈរលើមូលដ្ឋាននៃវិធាន ៧៤(៤)(ក) នៃវិធានផ្ទៃក្នុង។ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានបង្ហាញថា កិច្ចស៊ើបសួរដែលបានស្នើសុំអាចធ្វើទៅបានតាមវិធានផ្ទៃក្នុងឡើយ។ វិធានផ្ទៃក្នុងមិនបានចែងថា ដើមបណ្តឹងរដ្ឋប្បវេណីអាចពង្រីកការស៊ើបអង្កេតឡើយ។ សហព្រះរាជអាជ្ញាមិនបានពង្រីកការស៊ើបអង្កេតតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឡើយ ដែលដីកាសន្និដ្ឋាននេះអាចឱ្យដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំ (i) បំពេញកិច្ចស៊ើបសួរពេញលេញទាក់ទិននឹងទ្រព្យសម្បត្តិដែលជនត្រូវចោទមាន (ii) វិធានការរក្សាទុកទ្រព្យសម្បត្តិបែបនេះ ឬ (iii) ការកំណត់អត្តសញ្ញាណកម្មលើទ្រព្យសម្បត្តិដែលបានផ្ទេរ។ លទ្ធភាពក្នុងការពង្រីកការស៊ើបអង្កេតក្រៅពីវិសាលភាពនៃដីកាសន្និដ្ឋានទាំងឡាយ ដែលមានស្រាប់នោះស្ថិតនៅលើតែសហព្រះរាជអាជ្ញាតែប៉ុណ្ណោះ។ ដោយសារដើមបណ្តឹងរដ្ឋប្បវេណីមិនមានសិទ្ធិធ្វើសំណើសុំនេះ បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានឡើយ ដោយឈរលើមូលដ្ឋាននៃវិធាន ៧៤(៤)(ក)នៃវិធានផ្ទៃក្នុង។

---

[២២] សាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ ឯកសារលេខ: D250/3/2/1/5 ("សាលដីកាទាក់ទងនឹងដីកាសម្រេចរួម")។

[២៣] សាលដីកាទាក់ទងនឹងដីកាសម្រេចរួម កថាខណ្ឌ ១៧។

[២៤] សាលដីកាទាក់ទងនឹងដីកាសម្រេចរួម កថាខណ្ឌ ១៧ (ដោយយោងតែលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ទី១ ប៉ុណ្ណោះ)។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00578852



**វិធាន ២១ នៃវិធានផ្ទៃក្នុង**

១៧. វាជាភាពចាំបាច់ត្រូវពិចារណាថា តើអង្គបុរេជំនុំជម្រះមានកាតព្វកិច្ចធ្វើការពិចារណាលើបញ្ហានេះថាជាបណ្តឹងឧទ្ធរណ៍ដែលអាចទទួលយកបាន ដោយផ្អែកលើមូលដ្ឋាននានា ក្រៅពីវិធាន ៧៤(៤)(ក) នៃវិធានផ្ទៃក្នុងដែរឬទេ។ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបានតាមមូលដ្ឋាននៃវិធាន ២១ នៃវិធានផ្ទៃក្នុងឡើយ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បណ្តឹងឧទ្ធរណ៍បានផ្អែកតាមមូលដ្ឋាននៃសារណារបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលបានលើកឡើងថា វិធានផ្ទៃក្នុងមិនបានដាក់លក្ខខណ្ឌកម្រិតតឹងរ៉ឹងលើសហចៅក្រមស៊ើបអង្កេត តែទៅលើដីកាសន្និដ្ឋានទាំងឡាយរបស់សហព្រះរាជអាជ្ញាឡើយ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតត្រូវទទួលយកសំណើសុំនេះ ដោយផ្អែកលើមូលដ្ឋាននៃវិធាន ២១ នៃវិធានផ្ទៃក្នុងវិញ[២៥]។

១៨. វិធាន ២១ នៃវិធានផ្ទៃក្នុងចែងថា៖

> ១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖
>
> [...]
>
> គ-អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី។[២៦]

១៩. អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន ប្រសិនបើភាគីចោទប្រកាន់ថាមានការរំលោភបំពានលើការអនុវត្តសិទ្ធិ ដែលត្រូវបានការពារដោយ

---

[២៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៦, ១៩។

[២៦] វិធាន២១ នៃវិធានផ្ទៃក្នុង។

វិធាន ២១ នៃវិធានផ្ទៃក្នុង[២៧]។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានអះអាងថា វិធាន ២១ នៃវិធានផ្ទៃក្នុងចែងថា "[សហចៅក្រមស៊ើបអង្កេត] មានកាតព្វកិច្ចស៊ើបអង្កេតស្ថានភាពហិរញ្ញវត្ថុរបស់ជនត្រូវចោទ និងគ្រួសាររបស់ជនទាំងនេះ ពីព្រោះ [សហចៅក្រមស៊ើបអង្កេតត្រូវតែ] ធានា និងគោរពសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានសំណង និងត្រូវធានាថា សិទ្ធិនេះមិនមានតែលើក្រដាសតែប៉ុណ្ណោះទេ"[២៨]។ ដើម្បីជាមូលដ្ឋានគាំទ្រលើការអះអាងនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍បានអះអាងថា វិធាន ២១ នៃវិធានផ្ទៃក្នុងការពារ "សិទ្ធិជាសារវន្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានសំណង"[២៩]។ ម្ចាស់បណ្តឹងឧទ្ធរណ៍អះអាងថា សិទ្ធិជាសារវន្តនេះអាចគោរពទៅបានទាល់តែសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរដូចមាននៅក្នុងសំណើសុំ "ដើម្បីអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តួចផ្តើមការអនុវត្តដីកាដែលអាចសម្រេចលើសំណង"[៣០]។

២០. ម្ចាស់បណ្តឹងឧទ្ធរណ៍យល់ខុសលើការអនុវត្តសិទ្ធិទទួលបានសំណង។ យើងមិនឃើញមានបទប្បញ្ញត្តិចែងនៅក្នុងច្បាប់ជាធរមាន ឬចែងអំពីផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ឬរបស់ភាគីដទៃទៀត ដែលអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរលើបញ្ហាណាដែលស្ថិតក្រៅវិសាលភាពនៃកិច្ចស៊ើបសួរ ដូចបានកំណត់ដោយសហព្រះរាជអាជ្ញាឡើយ។ បន្ថែមលើចំណុចនេះ តាមរយៈការកំណត់ថាសិទ្ធិទទួលបានសំណងជាសិទ្ធិសារវន្ត អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងនោះ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនអាចពង្រីកប្រភេទនៃជនដែលត្រូវចេញសំណងពីពិរុទ្ធជនទៅជនត្រូវចោទបានទេ។ អង្គ

---

[២៧] អង្គបុរេជំនុំជម្រះបានពិចារណាឃើញការពីលើកមុនថា ការការពារសិទ្ធិដែលរកឃើញនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង អាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍មួយ។ សូមមើល សាលដីកាជាសាធារណៈ ដែលត្រូវបានកោសលុបលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ ឯកសារ A371/2/12។

[២៨] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៩។

[២៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៧។

[៣០] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៧។

បុរេជំនុំជម្រះយល់ឃើញថា តាមការពិនិត្យទៅលើវិធានផ្ទៃក្នុង មិនមានចំណុចដែលត្រូវមានមន្ទិលសង្ស័យអំពីប្រភេទនៃជនដែលត្រូវចេញសំណងឡើយ។

២១. អង្គបុរេជំនុំជម្រះបានពិចារណាបន្ថែមទៀតថា ម្ចាស់បណ្តឹងឧទ្ធរណ៍បានផ្អែកសំណើសុំ និងបណ្តឹងឧទ្ធរណ៍របស់ខ្លួនមួយផ្នែកលើការអះអាងដោយខុសថា ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះត្រូវទទួលបានសំណង។ យោងតាមសំណើ[៣១] និងបណ្តឹងឧទ្ធរណ៍[៣២] ម្ចាស់បណ្តឹងឧទ្ធរណ៍សន្និដ្ឋានថា ខ្លួនមានសិទ្ធិទទួលបានសំណង។ ដើមបណ្តឹងរដ្ឋប្បវេណីមានត្រឹមតែសិទ្ធិអាចទទួលបានការផ្តល់សំណង ដែលអង្គជំនុំជម្រះមានសមត្ថកិច្ចសម្រេចលើជនដែលត្រូវបានកាត់ឱ្យជាប់ទោសតែប៉ុណ្ណោះ។ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទាមទារសំណង ប៉ុន្តែមិនមែនជាការធានាថានឹងទទួលបានសំណងតែម្តងនោះទេ។ ការសម្រេចលើការផ្តល់សំណងគឺស្ថិតលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះដែលមានសមត្ថកិច្ច ក្រោយពីការសម្រេចឱ្យជាប់ទោសតែប៉ុណ្ណោះ។ ដូច្នេះ សិទ្ធិនេះគឺសិទ្ធិទាមទារសំណង មិនមែនសិទ្ធិទទួលបានសំណងឡើយ ដែលអាចការពារដោយអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។

២២. ម្ចាស់បណ្តឹងឧទ្ធរណ៍អះអាងថា ដើម្បី "អនុវត្ត" "សិទ្ធិជាមូលដ្ឋានក្នុងការទទួលបាននូវសំណង" សហចៅក្រមស៊ើបអង្កេតត្រូវ "ចាត់វិធានការធ្វើយ៉ាងណាអាចឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានលទ្ធភាពផ្តួចផ្តើម" សម្រាប់ការអនុវត្ត[៣៣]។ ម្ចាស់បណ្តឹងឧទ្ធរណ៍ហាក់ដូចជាមានសំអាងទៅអត្ថបទនៃវិធាន ១១៣ នៃវិធានផ្ទៃក្នុង ដើម្បីពន្យល់អំពីមូលហេតុអ្វី

---

[៣១] ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងនៅក្នុងសំណើសុំថា សហចៅក្រមស៊ើបអង្កេតត្រូវដឹកនាំកិច្ចស៊ើបសួរដែលបានស្នើសុំ ពីព្រោះ "[ទ្រព្យ]សម្បត្តិដែលជនត្រូវចោទមាន[ស៊ិក]ដោយស្របច្បាប់គឺ[ស៊ិក]ជាទ្រព្យដែលជាប់ កាតព្វកិច្ចសំរាប់ធានាដល់ការសងជាសំណងរដ្ឋប្បវេណីសំរាប់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ នៅពេលដែលមានសេចក្តីសម្រេចស្ថាពររបស់តុលាការដែលមានខ្លឹមសារថាជនត្រូវចោទពិតជាបានប្រព្រឹត្តឧក្រិដ្ឋកម្មមែននោះ" សំណើ កថាខណ្ឌ២។

[៣២] សូមមើល ឧទាហរណ៍ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៧, ១៨, ១៩។ នៅក្នុងបណ្តឹងឧទ្ធរណ៍ ម្ចាស់បណ្តឹងឧទ្ធរណ៍ទទួលស្គាល់ថា ការផ្តល់សំណង "អាចធ្វើបាន"។ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៧។

[៣៣] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៧។

00578855



បានជាត្រូវមានការអនុញ្ញាតតាមសំណូមពរមុនពេលមានការផ្តន្ទាទោស និងការផ្តល់នូវសំណង។ វិធាន ១១៣ នៃវិធានផ្ទៃក្នុង ចែងថា:

"វិធាន ១១៣: ការអនុវត្តទោស និង សំណងរដ្ឋប្បវេណី

១. ការអនុវត្តទោសត្រូវធ្វើតាមការផ្តួចផ្តើមគំនិតរបស់សហព្រះរាជអាជ្ញា។ ការអនុវត្តការជួសជុលសំណង ត្រូវធ្វើតាមគំនិតផ្តួចផ្តើមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ..."[៣៤]។

២៣. ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ វិធាន ១១៣ នៃវិធានផ្ទៃក្នុងមិនបានផ្តល់សិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការផ្តួចផ្តើមអនុវត្តការជួសជុលសំណងនៅដំណាក់-កាលបុរេជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនោះឡើយ។ វិធាន ២៣ នៃវិធានផ្ទៃក្នុង *ស្ទួន៥* គូសបញ្ជាក់ថា ការសងសំណងអាចត្រូវបានធ្វើឡើងប្រឆាំងតែនឹងពិរុទ្ធជនប៉ុណ្ណោះ។ ដោយសារតែការសងសំណងអាចត្រូវបានធ្វើឡើងប្រឆាំងតែនឹងពិរុទ្ធជននោះ ការសងសំណងមិនអាចអនុវត្តបានប្រឆាំងទៅនឹងជនដែលមិនត្រូវបានចោទប្រកាន់ ជនដែលមិនត្រូវបានជំនុំជម្រះទោស និងជនដែលមិនត្រូវបានផ្តន្ទាទោសនោះឡើយ។ វាស្ថិតនៅក្រៅយុត្តាធិការរបស់អង្គជំនុំជម្រះនេះ ក្នុងការចាត់វិធានការអនុវត្តការសងសំណងមុនពេលកំណត់នេះ ពីព្រោះអង្គជំនុំជម្រះដែលមានសមត្ថកិច្ចបានសម្រេចអំពីពិរុទ្ធភាព បន្ទាប់ពីមានការជំនុំជម្រះក្តីផ្អែកតាមការចោទប្រកាន់ទាំងឡាយ បានធ្វើកំណត់ហេតុអំពីការផ្តន្ទាទោស និងបានកំណត់អំពីការសងសំណង ប្រសិនបើមាន។ ដូចបានរៀបរាប់ខាងក្រោម បើទោះជាដើមបណ្តឹងរដ្ឋប្បវេណីមានផលប្រយោជន៍ក្នុងទ្រព្យសម្បត្តិរបស់ជនត្រូវចោទ ទាំងផលប្រយោជន៍ខ្លួនឯង ទាំងសិទ្ធិពាក់ព័ន្ធនឹងផលប្រយោជន៍នេះ មិនត្រូវបានបញ្ជាក់ឲ្យបានច្បាស់លាស់ឡើយ។ អនុលោមតាមវិធានរបស់តុលាការនេះ អង្គហេតុដែលថាផលប្រយោជន៍ ឬសិទ្ធិមិនត្រូវបានបញ្ជាក់ឲ្យច្បាស់លាស់នោះ មិនចាំបាច់ត្រូវចាត់វិធានការឥឡូវនេះទេ។ ការយល់ព្រមតាមសំណូមពរដែលបានស្នើសុំនឹងធ្វើឲ្យអង្គបុរេជំនុំជម្រះ និងសហចៅក្រមស៊ើបអង្កេតមានតួនាទីហួសពីយុត្តាធិការរួមរបស់យើង។

២៤. អង្គបុរេជំនុំជម្រះធ្វើការកត់សម្គាល់លើអង្គហេតុដែលថា ការកំណត់នេះមានភាពជាក់-លាក់ចំពោះតុលាការនេះ។ នៅចំពោះមុខតុលាការអន្តរជាតិផ្សេងទៀត ដើមបណ្តឹងរដ្ឋ-

---

[៣៤] វិធាន១១៣ នៃវិធានផ្ទៃក្នុង។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00578856



ប្បវេណី និងជនរងគ្រោះ អាចឃើញថា កិច្ចស៊ើបសួរទាំងឡាយរួមទាំងការតាមដាន ការបង្កក ការរឹបអូស និងការចាត់វិធានការការពារផ្សេងទៀត អាចត្រូវបានអនុវត្តមុនពេលធ្វើការផ្តន្ទាទោស និងការផ្តល់សំណង។ ក្រមខណ្ឌច្បាប់របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ("ICC") ចែងអំពីវិធានការទាំងអស់នេះ។ អំណាចរបស់តុលាការ ICC ក្នុងការបង្គាប់ឱ្យមានសំណងដល់ជនរងគ្រោះម្នាក់ៗ ត្រូវបានចែងយ៉ាងច្បាស់លាស់ នៅក្នុងមាត្រា ៧៥ នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម[៣៥]។ ជាការសំខាន់ លក្ខន្តិកៈទីក្រុងរ៉ូមប្រគល់សិទ្ធិអំណាចឱ្យអង្គបុរេជំនុំជម្រះស្វែងរកកិច្ចសហប្រតិបត្តិការពីបណ្តារដ្ឋ ដើម្បី "ចាត់វិធានការការពារក្នុងគោលបំណងរឹបអូស ជាពិសេស សម្រាប់ជាប្រយោជន៍សំខាន់ សម្រាប់ជនរងគ្រោះ"[៣៦]។ វិធានការទាំងអស់នេះ រួមមាន "ការកំណត់អត្តសញ្ញាណ ការតាមដាន និងការបង្កក ឬការរឹបអូសផលនៃបទល្មើស ចលនទ្រព្យ និងអចលនទ្រព្យ"[៣៧]។ ជនរងគ្រោះ ដែលបានធ្វើសំណើសុំសំណងអាចស្នើដោយផ្ទាល់សុំឱ្យអង្គបុរេជំនុំជម្រះឱ្យធ្វើការពិចារណាចាត់វិធានការការពារដូចបានលើកឡើងខាងលើ[៣៨]។ លើសពីនេះទៀត វិធាននៃនីតិវិធី និងភស្តុតាង បានបង្កើតនូវយន្តការអនុវត្តសម្រាប់ការផ្តល់សំណងដែលប្រធានតុលាការត្រូវទទួលបន្ទុកក្នុងការស្វែងរកកិច្ចសហប្រតិបត្តិការពីបណ្តារដ្ឋនានា ដើម្បីរឹបអូសចលនទ្រព្យ និងអចលនទ្រព្យទាំងឡាយរបស់ពិរុទ្ធជន[៣៩]។ អង្គបុរេជំនុំជម្រះនៃតុលាការ ICC បានបកស្រាយបទបញ្ញត្តិច្បាប់ទាំងអស់នេះថាជាការផ្តល់យុត្តាធិការដល់អង្គជំនុំជម្រះក្នុងការចាត់វិធានការការពារ ដើម្បីធានាការអនុវត្តការផ្តល់សំណងនាពេល

---

[៣៥] លក្ខខន្តិកៈក្រុងរូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ឯកសារអង្គការសហប្រជាជាតិលេខ A/CONF.183/9, *ចូលជាធរមាន*នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០២ ["លក្ខខន្តិកៈក្រុងរូម"] មាត្រា៧៥។

[៣៦] លក្ខខន្តិកៈក្រុងរូម មាត្រា៥៧(៣)(ង)។

[៣៧] លក្ខខន្តិកៈក្រុងរូម មាត្រា៩៣(១)(ឆ) ដូចដែលត្រូវបានយោងដោយលក្ខខន្តិកៈក្រុងរូម មាត្រា៥៧(៣)(ង)។

[៣៨] វិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ ICC, ឯកសារអង្គការសហប្រជាជាតិ ICC-ASP/1/3 (2002) ["វិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ ICC"] វិធាន៩៩(១)។

[៣៩] វិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ ICC វិធាន២១៧-២១៨។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

អនាគត[៤០]។ អង្គបុរេជំនុំជម្រះនៃតុលាការ ICC ដោយពឹងផ្អែកយ៉ាងខ្លាំងលើក្របខណ្ឌច្បាប់ជាក់លាក់នេះរបស់ ICC បានយល់ឃើញថា:

> តាមការយល់ឃើញរបស់អង្គជំនុំជម្រះ ផែនការនៃការសងសំណងដែលបានចែងនៅក្នុងច្បាប់លក្ខន្តិកៈមិនមែនគ្រាន់តែជាចំណុចដោយឡែកតែមួយរបស់លក្ខន្តិកៈប៉ុណ្ណោះទេ តែវាក៏ជាចំណុចសំខាន់ជាគន្លឹះមួយផងដែរ។ [...] នៅក្នុងបរិបទនេះ អង្គជំនុំជម្រះពិចារណាឃើញថា ការតាមដាន ការកំណត់អត្តសញ្ញាណ និងការបង្កក ឬការរឹបអូសពីដំបូងនូវទ្រព្យសម្បត្តិ និងទ្រព្យធនរបស់ជនណាម្នាក់ដែលរឿងក្តីត្រូវបានធ្វើឡើងប្រឆាំងនឹងជននោះតាមរយៈការចេញដីកាចាប់ខ្លួន ឬដីកាកោះហៅឱ្យចូលខ្លួន ក៏ចាំបាច់ផងដែរ[...]"។ [ការគូសបញ្ជាក់បន្ថែម][៤១]។

២៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សិទ្ធិក្នុងការមានលទ្ធភាពសុំឱ្យផ្តល់សំណងដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងមានតិចតួចណាស់ បើប្រៀបទៅនឹងការសងសំណងនៅតុលាការ ICC។ អង្គជំនុំជម្រះមានសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការផ្តល់សំណងដែលសំដៅតែលើសំណងជាសមូហភាព និងសំណងផ្លូវចិត្ត មានលទ្ធភាពតិចជាងបើប្រៀបទៅនឹងក្នុងការផ្តល់សិទ្ធិអំណាចបង្គាប់ឱ្យមានការសងសំណង ដែលត្រូវបានអនុញ្ញាតនៅក្នុងមាត្រា ៧៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម។ លើសពីនេះទៀត នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ អង្គជំនុំជម្រះគ្មានសិទ្ធិអំណាចផ្លូវច្បាប់ក្នុងការបង្គាប់ឱ្យមានការបង្កកទ្រព្យសម្បត្តិមុនពេលជំនុំជម្រះក្តីនោះឡើយ ដែលចំណុចនេះត្រូវបានចែងយ៉ាងច្បាស់លាស់នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម និងវិធាននីតិវិធី និងភស្តុតាងនៃតុលាការ ICC។ ក្របខណ្ឌច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញមិនបានផ្តល់យុត្តាធិការឱ្យផ្នែកណាមួយរបស់តុលាការនេះក្នុងការអនុវត្តការផ្តល់សំណងនោះឡើយ។ ជាចុងក្រោយ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នីតិវិធីដែលពាក់ព័ន្ធនឹងផែនការនៃការសងសំណងនៅចំពោះមុខ

---

[៤០] សេចក្តីសម្រេចពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៦ និងការរួមបញ្ចូលនូវឯកសារនានាទៅក្នុងកំណត់ហេតុនៃរឿងក្តីប្រឆាំងនឹងលោក Thomas Lubanga Dyilo រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Thomas Lubanga Dyilo*, ICC-01/04-01/06, អង្គបុរេជំនុំជម្រះ I ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៦ ("រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Lubanga*") កថាខណ្ឌ ១៣០ ដល់១៤១។

[៤១] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Lubanga* កថាខណ្ឌ១៣៦ (គូសបញ្ជាក់បន្ថែម) (ជើងទំព័រ...)។



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

តុលាការ ICC ឆ្លុះបញ្ចាំងពីលក្ខណៈពឹងផ្អែកលើសន្ធិសញ្ញារបស់ប្រព័ន្ធទីក្រុងរ៉ូម ដែលសកម្មភាពផ្លូវច្បាប់ត្រូវតែអនុវត្តក្នុងទម្រង់នៃការស្នើសុំកិច្ចសហប្រតិបត្តិការពីបណ្តារដ្ឋនានា[៤២]។ តួនាទីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងប្រព័ន្ធតុលាការជាតិនៃព្រះរាជាណាចក្រកម្ពុជា ខុសគ្នាទាំងស្រុងទៅនឹងមូលដ្ឋានច្បាប់របស់តុលាការ ICC។ ភាពខុសគ្នាទាំងឡាយនៅក្នុងក្របខណ្ឌច្បាប់ និងវិសាលភាពផ្នែកយុត្តាធិការរបស់តុលាការ ICC និង អង្គជំនុំជម្រះវិសាមញ្ញ ទាក់ទិនទៅនឹងការសងសំណងដល់ជនរងគ្រោះ មានទំហំធំធេង និងគួរឱ្យកត់សម្គាល់។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា តាមរយៈវិធាន និងគោលការណ៍នានា អង្គបុរេជំនុំជម្រះមានកាតព្វកិច្ចគោរពវិធាន និងគោលការណ៍ដែលមានកំណត់នៅក្នុងក្របខណ្ឌច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញ។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ អង្គបុរេជំនុំជម្រះមិនអាចធ្វើតាមការណែនាំលើបញ្ហានេះពីការអនុវត្តរបស់តុលាការ ICC នោះទេ។ លក្ខន្តិកៈទីក្រុងរ៉ូម និងវិធាននានាដែលអាចអនុវត្តនៅចំពោះមុខតុលាការ ICC មិនមានភាពដូចគ្នាទៅនឹងបទប្បញ្ញត្តិពាក់ព័ន្ធនៅក្នុងឯកសារជាធរមានរបស់អង្គជំនុំជម្រះវិសាមញ្ញឡើយ។

២៦. ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានបង្ហាញថា ការខកខានរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងការយល់ព្រមតាមសំណើសុំ រំលោភលើសិទ្ធិជាមូលដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានការពារតាមរយៈវិធាន ២១ នៃវិធានផ្ទៃក្នុង។

២៧. ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងទឡ្ហីករណ៍នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនថា វិធាន ២១ នៃវិធានផ្ទៃក្នុង តម្រូវឱ្យសហចៅក្រមស៊ើបអង្កេតដឹកនាំកិច្ចស៊ើបសួរដោយដកស្រង់នូវលិខិតុបករណ៍ និងសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សអន្តរជាតិ[៤៣]។ ប្រទេសកម្ពុជាគឺជាប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀង និងសន្ធិសញ្ញាអន្តរជាតិជាច្រើន រួមទាំងកតិកាសញ្ញា ស្តីពី

[៤២] ដូចនេះ បណ្តារដ្ឋភាគីនៃកតិកាសញ្ញាទីក្រុងរ៉ូមមានកាតព្វកិច្ចផ្អែកលើសន្ធិសញ្ញា ក្នុងការសហការជាមួយនឹងដីកានានារបស់អង្គជំនុំជម្រះរបស់តុលាការ ICC។ *សូមមើល* កតិកាសញ្ញាទីក្រុងរ៉ូម មាត្រា ៨៦។

[៤៣] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២០។



E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")[៤៤]។ ចំពោះការចោទប្រកាន់ទៅលើការរំលោភលើលិខិតុបករណ៍ និងសន្ធិសញ្ញាអន្តរជាតិ ដែលអាចអនុវត្តនៅក្នុងប្រទេសកម្ពុជា ដែលទាក់ទងនឹងសិទ្ធិដែលអាចយកមកអនុវត្តបាននៅក្នុងក្របខណ្ឌតុលាការនេះ វិធាន ២១ នៃវិធានផ្ទៃក្នុងចែងថា សិទ្ធិរបស់ជនទាំងឡាយនៅចំពោះមុខតុលាការនេះ រួមទាំងជនរងគ្រោះផងដែរ ត្រូវទទួលបាននូវការការពារ[៤៥]។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានកំណត់មាត្រា ២(៣) នៃកតិកាសញ្ញា ICCPR ថាបានចែងអំពីសិទ្ធិក្នុងការទទួលបាននូវដំណោះស្រាយដោយសក្តិសម[៤៦]។ មាត្រា ២(៣) ចែងថា រដ្ឋជាភាគីនៃកតិកាសញ្ញា ICCPR មានភារៈកិច្ចដូចខាងក្រោមៈ

(ក) ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួន ដែលយកត្រូវបានទទួលស្គាល់ដោយកតិកាសញ្ញានេះ ជននោះមានសិទ្ធិទទួលបានការដោះស្រាយដោយប្រសិទ្ធភាព ទោះបីការរំលោភនោះត្រូវបានប្រព្រឹត្តដោយជនដែលបំពេញមុខនាទីផ្លូវការក៏ដោយ។

(ខ) ធានាថា ជនណាដែលប្តឹងឲ្យមានការដោះស្រាយបែបនេះ ត្រូវមានសិទ្ធិឲ្យអាជ្ញាធរមានសមត្ថកិច្ចខាងយុត្តិធម៌ ខាងរដ្ឋបាល ឬខាងនីតិបញ្ញត្តិ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀតសម្រេចឲ្យខ្លួន ដោយយោងតាមច្បាប់របស់រដ្ឋនោះ និងត្រូវបង្កើតលទ្ធភាពនៃការប្តឹងទៅតុលាការផង។

---

[៤៤] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, 999 UNTS 171 និង 1057 UNTS 407 ("កតិកាសញ្ញា ICCPR")។

[៤៥] ទោះបីជាច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀង អ.វ.ត.ក បានបូកបញ្ចូលយ៉ាងច្បាស់លាស់ តែចំពោះការការពារនូវការជំនុំជម្រះក្តីដោយយុត្តិធម៌នៃមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញា ICCPR ក៏ដោយ ប្រទេសកម្ពុជាគឺជាប្រទេសភាគីផ្តល់សច្ចាប័ន និងមានកាតព្វកិច្ចក្នុងការគោរពតាមរាល់បញ្ញត្តិទាំងអស់របស់កតិកាសញ្ញា ICCPR ។ ក្រោមកតិកាសញ្ញា ICCPR តុលាការដែលអនុវត្តច្បាប់របស់រដ្ឋជាភាគីមានកាតព្វកិច្ចដូចគ្នា នឹងរដ្ឋជាភាគី (នៅពេលដែលអាចអនុវត្តបាន) ផងដែរ។ សូមមើល សេចក្តីអត្ថាធិប្បាយទូទៅ លេខ៣១ កថាខណ្ឌទី៤។ តុលាការនេះគឺជាតុលាការដែលត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវរបស់ព្រះរាជាណាចក្រកម្ពុជា ហេតុនេះហើយត្រូវការពារសិទ្ធិទាំងឡាយដែលបានរកឃើញនៅក្នុងកតិកាសញ្ញា ICCPR ចំពោះវិសាលភាព ដែលថា សិទ្ធិនេះគ្មានទំនាស់ជាមួយនឹងសិទ្ធិ និងកាតព្វកិច្ចដែលមាននៅក្នុងឯកសារដែលសំខាន់របស់តុលាការនេះ។

[៤៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២០។

00578860



(គ) ធានាថា អាជ្ញាធរមានសមត្ថកិច្ចត្រូវអនុវត្តឱ្យបាននូវដំណោះស្រាយដែលបានសម្រេចហើយ[៤៧]។

២៨. ម្ចាស់បណ្តឹងឧទ្ធរណ៍ក៏បានកត់សម្គាល់ឃើញផងដែរថា សេចក្តីអត្ថាធិប្បាយទូទៅ លេខ ៣១ របស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានណែនាំថា មាត្រា ២(៣) នៃកតិកាសញ្ញា ICCPR កំណត់ថា "បណ្តារដ្ឋភាគីត្រូវសងសំណងដល់ជនដែលគេបានរំលោភបំពានលើសិទ្ធិដែលទទួលស្គាល់ដោយកតិកាសញ្ញា។ ប្រសិនបើមិនមានការសងសំណងដល់ជនដែលគេបានរំលោភបំពានលើសិទ្ធិនោះទេ កាតព្វកិច្ចក្នុងការរកដំណោះស្រាយដោយប្រសិទ្ធភាព ដែលជាស្នូលគឺសំខាន់នៅក្នុងមាត្រា២ កថាខណ្ឌ៣ មិនត្រូវបានបំពេញឡើយ"[៤៨]។

២៩. អង្គបុរេជំនុំជម្រះបានពិចារណាអំពីបញ្ហាថាតើសិទ្ធិដែលផ្តល់ឱ្យជនរងគ្រោះអនុលោមតាមលិខិតុបករណ៍ និងកិច្ចព្រមព្រៀងអន្តរជាតិគ្របដណ្តប់លើបញ្ហាពិសេសថាតើសិទ្ធិក្នុងការទទួលបាននូវដំណោះស្រាយដោយប្រសិទ្ធភាព តម្រូវឱ្យសហចៅក្រមស៊ើបអង្កេតដឹកនាំកិច្ចស៊ើបសួរដែលបានស្នើសុំដែរឬទេ។ សិទ្ធិក្នុងការទទួលបាននូវដំណោះស្រាយដោយមានប្រសិទ្ធភាព ដែលមានបំណងការពារជនរងគ្រោះ គឺជាសិទ្ធិដែលអនុវត្តបន្ទាប់ពីមានការយល់ឃើញថាមានការរំលោភបំពាន។ គ្មានការយល់ឃើញថាមានការរំលោភបំពានណាមួយ អាចធ្វើឡើងនៅក្នុងដំណាក់កាលមុនការជំនុំជម្រះក្តីនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ។

៣០. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានអះអាងថា ដីកាដែលត្រូវបានជំទាស់ បានធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីពុំមានដំណោះស្រាយដោយប្រសិទ្ធភាព

---

[៤៧] កតិកាសញ្ញា ICCPR មាត្រា២(៣)។

[៤៨] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២០ ដែលបានដកស្រង់សេចក្តីអត្ថាធិប្បាយទូទៅ លេខ៣១[៨០] របស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ: លក្ខណៈនៃកាតព្វកិច្ចផ្លូវច្បាប់ទូទៅដែលបានដាក់លើបណ្តារដ្ឋជាភាគីនៃកតិកាសញ្ញា ឯកសារ UN CCPR/C/21/Rev.1/Add.13 (ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤) ("[illegible]អត្ថាធិប្បាយទូទៅលេខ៣១") កថាខណ្ឌ ១៦។



E.C.C.C * C.E.T.C. * PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

នោះទេ[៤៩]។ ម្ចាស់បណ្តឹងឧទ្ធរណ៍ក៏មិនបានតវ៉ាថា ប្រសិនបើគ្មានសំណូមពរទេនោះ ដើមបណ្តឹងរដ្ឋប្បវេណីនឹងមិនទទួលបាននូវដំណោះស្រាយដោយប្រសិទ្ធភាពនោះដែរ។ ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងថា "កិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវតែគោរពតាមបទដ្ឋានអន្តរជាតិ" [៥០] និងថា ដីកាដែលត្រូវបានជំទាស់ "បានរំលោភបំពានលើសន្ធិសញ្ញាទាំងឡាយដែលនៅជាធរមាន និងចងកាតព្វកិច្ច [sic]"[៥១]។ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដោយគ្រាន់តែលើកឡើងថា តុលាការមានកាតព្វកិច្ចក្នុងការស៊ើបអង្កេត ដើម្បីអនុវត្តសំណាងដែលពិរុទ្ធជនចេញសងដោយប្រសិទ្ធភាព"[៥២] មិនបានគាំទ្រដល់ការតវ៉ារបស់ខ្លួនដែលថា បើមិនធ្វើការស៊ើបអង្កេតទេ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនទទួលបាននូវដំណោះស្រាយដោយប្រសិទ្ធភាពនោះឡើយ។ ចំពោះហេតុផលដូចគ្នានេះដែរ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានធ្វើសេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងលិខិតុបករណ៍ និងសន្ធិសញ្ញាអន្តរជាតិផ្សេងទៀតដែលបានដកស្រង់នៅក្នុងបណ្តឹងឧទ្ធរណ៍នោះឡើយ។

៣១. អង្គបុរេជំនុំជម្រះសង្កេតឃើញថា គណៈកម្មាធិការសិទ្ធិមនុស្សបានទទួលស្គាល់ថា នៅក្នុងរឿងក្តីមួយចំនួន សិទ្ធិក្នុងការទទួលបាននូវដំណោះស្រាយដោយប្រសិទ្ធភាពអាចមានវិធានការបណ្តោះអាសន្ន[៥៣]។ ម្ចាស់បណ្តឹងឧទ្ធរណ៍ខកខានមិនបានលើកឡើងថា វិធាន

---

[៤៩] នៅក្នុងមូលដ្ឋានបណ្តឹងឧទ្ធរណ៍ដាច់ដោយឡែកមួយ ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងថា ផ្អែកលើការផុតកំណត់នៃអាជ្ញាយុកាលសម្រាប់បណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការនៃប្រទេសកម្ពុជា តុលាការកម្ពុជាមិនអាចអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីដាក់បណ្តឹងរដ្ឋប្បវេណីបានទេ។ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៥។ ដោយសរសេរនៅក្នុងបរិបទដែលមានបំណងធ្វើជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ សេចក្តីថ្លែងការណ៍នេះមិនត្រូវបានធ្វើឡើងដើម្បីគាំទ្រដល់ការយោងលើមាត្រា ២(៣) នៃកតិកាសញ្ញា ICCPR។

[៥០] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២០។

[៥១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២២។

[៥២] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២២។

[៥៣] "គណៈកម្មាធិការយល់ឃើញថែមទៀតថា សិទ្ធិក្នុងការទទួលបាននូវការដោះស្រាយដោយប្រសិទ្ធភាព នៅក្នុងករណីខ្លះអាចកំណត់លក្ខខណ្ឌឱ្យរដ្ឋជាបណ្តារដ្ឋជាភាគីថែង និងអនុវត្តវិធានការបណ្តោះអាសន្ន ដើម្បីចៀសវាងកុំឱ្យមានការរំលោភបំពានតទៅទៀត និងដើម្បីខិតខំជួសជុលការខូចខាតដែលអាចបណ្តាលមកពីការរំលោភបំពាននេះ នៅឱកាសដែលអាចធ្វើបានឆាប់បំផុត"។ សេចក្តីអត្ថាធិប្បាយទូទៅ លេខ៣១ កថាខណ្ឌ ១៩។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ការបណ្តោះអាសន្នដែលបានស្នើឡើងគឺជាវិធានការបណ្តោះអាសន្ន និងថាវិធានការបណ្តោះអាសន្ននេះ បានបំពេញលក្ខខណ្ឌកំណត់សម្រាប់វិធានការនេះស្របតាមកតិកាសញ្ញា ICCPR។ បុគ្គលដែលដាក់ពាក្យសុំចាត់វិធានការបណ្តោះអាសន្នត្រូវបង្ហាញថា ខ្លួនមានសិទ្ធិធ្វើការតវ៉ា និងថា ព្យសនកម្មដែលមិនអាចជួសជុលបានចំពោះការតវ៉ានេះ នឹងកើតមានឡើង ប្រសិនបើវិធានការដែលត្រូវបានស្នើសុំមិនត្រូវបានចែង និងមិនត្រូវបានអនុវត្តនោះ[៥៤]។ បណ្តឹងឧទ្ធរណ៍មិនបាននិយាយអំពីការតវ៉ារបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដោយមានការបញ្ជាក់ ឬការបំភ្លឺឲ្យបានគ្រប់គ្រាន់ឡើយ ហើយម្ចាស់បណ្តឹងឧទ្ធរណ៍ក៏មិនបានជូនដំណឹងដល់អង្គបុរេជំនុំជម្រះ អំពីមូលហេតុអ្វីបានជាវិធានការបណ្តោះអាសន្នគឺជាវិធានការចាំបាច់ និងសមស្របនៅក្នុងករណីនេះឡើយ។ អង្គបុរេជំនុំជម្រះនឹងមិនពិចារណាពាក់ព័ន្ធនឹងបញ្ហាថា តើម្ចាស់បណ្តឹងឧទ្ធរណ៍ស្នើសុំប្រភេទជាក់លាក់មួយនៃការជួសជុលសំណងនៅក្នុងបណ្តឹងឧទ្ធរណ៍នោះឡើយ។ ដោយសារតែម្ចាស់បណ្តឹងមិនបានបង្ហាញថា ផ្អែកលើផលប្រយោជន៍ដែលមានស្រាប់ វិធានការបណ្តោះអាសន្នគួរតែត្រូវបានផ្តល់ជូន បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានដោយផ្អែកលើកាតព្វកិច្ចទាំងឡាយរបស់តុលាការនេះ អនុលោមតាមកតិកាសញ្ញា ICCPR និងវិធាន ២១ នៃវិធានផ្ទៃក្នុងទេ។

៣២. បន្ទាប់ពីយល់ឃើញថាសេចក្តីសន្និដ្ឋានរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍សម្រាប់ការអនុវត្តវិធាន ២១ នៃវិធានផ្ទៃក្នុង មិនមានភាពជាក់លាក់ ឬច្បាស់លាស់គ្រប់គ្រាន់ទេនោះ អង្គបុរេជំនុំជម្រះនឹងមិនធ្វើការពិចារណាអំពីមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ដែលតម្រូវឲ្យអង្គបុរេជំនុំជម្រះត្រូវសន្និដ្ឋានពាក់ព័ន្ធនឹងការទាមទារដែលបានធ្វើឡើង និងសេចក្តីសន្និដ្ឋានដែលគាំទ្រ

---

[៥៤] វិធាន ៩២ នៃវិធាននីតិវិធីរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ចែងថា:

មុនពេលដាក់ចេញនូវការយល់ឃើញអំពីទំនាក់ទំនងចំពោះរដ្ឋភាគីដែលពាក់ព័ន្ធ គណៈកម្មាធិការអាចធ្វើការជូនដំណឹងថា រដ្ឋដែលខ្លួនមានការយល់ឃើញពាក់ព័ន្ធថាតើវិធានការបណ្តោះអាសន្នអាចមានបំណងជៀសវាងមិនឲ្យមានព្យសនកម្មដែលមិនអាចជួសជុលបានចំពោះជនរងគ្រោះដោយសារការរំលោភបំពាន ដែលបានលើកឡើងដែរឬទេ។ នៅក្នុងការធ្វើដូច្នេះ គណៈកម្មាធិការត្រូវជូនដំណឹងដល់រដ្ឋភាគីដែល ពាក់ព័ន្ធថាការលើកឡើងនូវទស្សនៈយល់ឃើញរបស់ខ្លួនអំពីវិធានការបណ្តោះអាសន្ន មិនធ្វើការសម្រេចលើខ្លឹមសារនៃទំនាក់ទំនងនោះទេ។

វិធាននីតិវិធីរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ឯកសាររបស់អង្គការសហប្រជាជាតិ CCPR/C/3/វិសោធនកម្មលើកទី8, ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៥ វិធាន ៩២។

ដល់ការទាមទារនេះទេ។ អង្គបុរេជំនុំជម្រះគូសបញ្ជាក់ថា វិធានការដែលបានស្នើសុំដោយម្ចាស់បណ្តឹងឧទ្ធរណ៍ រួមទាំងការដឹកនាំកិច្ចស៊ើបសួរ ការតាមដានអំពីប្រភពដែលរកបានទ្រព្យសម្បត្តិ និងការអនុវត្តវិធានការសម្រាប់ការរក្សាទុកទ្រព្យសម្បត្តិ គឺជាវិធានការដែលត្រូវបានច្បាប់អនុញ្ញាត។ អង្គជំនុំជម្រះនេះមិនមានយុត្តាធិការក្នុងការចេញដីកានានាដែលមិនស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការនេះទេ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងច្បាប់ជាធរមានរបស់តុលាការនេះ។ នៅក្នុងបរិបទនៃបណ្តារដ្ឋជាភាគីនៃកតិកាសញ្ញា ICCPR តុលាការត្រូវទទួលខុសត្រូវក្នុងការធានាអំពីការអនុវត្តការការពារ និងសិទ្ធិដែលឃើញមានចែងនៅក្នុងកតិកាសញ្ញា ICCPR ដែលស្ថិតក្រោមការអនុវត្តយុត្តាធិការរបស់ខ្លួន និងមិនមានលក្ខណៈទូទៅនោះទេ។ នៅពេលដែលបញ្ហានៅក្នុងសំណើស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ អង្គជំនុំជម្រះនេះយល់ឃើញថា បណ្តឹងឧទ្ធរណ៍ទាំងឡាយបានរៀបចំដោយផ្អែកលើសិទ្ធិរបស់បុគ្គលទាំងអស់នោះដែលត្រូវបានការពារដោយកតិកាសញ្ញា ICCPR ព្រមទាំងកាតព្វកិច្ចទាំងឡាយរបស់រដ្ឋជាភាគីពាក់ព័ន្ធទៅនឹងសិទ្ធិ និងបុគ្គលទាំងអស់នោះ។ តុលាការត្រូវបានកំណត់ការងារដោយយុត្តាធិការរបស់ខ្លួន និងមិនអាចពង្រីកយុត្តាធិការដោយផ្អែកលើកាតព្វកិច្ចរបស់រដ្ឋជាភាគីនៃកតិកាសញ្ញា ICCPR បានទេ។ ក្រៅពីនេះ ការពង្រីកយុត្តាធិការគឺជាអំពើខុសច្បាប់។

៣៣. អង្គបុរេជំនុំជម្រះយល់ឃើញថា វាជាការសមរម្យក្នុងការពិនិត្យថាតើវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលត្រូវបានបកស្រាយយ៉ាងទូលំទូលាយ ចែងអំពីមូលដ្ឋានសម្រាប់ការទទួលយកដែរឬទេ។ អង្គបុរេជំនុំជម្រះមិនអាចកំណត់ឃើញអំពីផលប្រយោជន៍បច្ចុប្បន្នរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ក្រៅពីសិទ្ធិក្នុងការស្នើសុំសំណងនៅដំណាក់កាលសមស្របនៃកិច្ចដំណើរការនីតិវិធី។ ផលប្រយោជន៍នេះមិនត្រូវបានធ្វើឲ្យអន្តរាយដោយសារដីកាដែលត្រូវបានជំទាស់នោះទេ។ អង្គបុរេជំនុំជម្រះមិនអាចកំណត់បង្ហាញអំពីផលប្រយោជន៍បច្ចុប្បន្នរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍នោះទេ ប៉ុន្តែកត់សម្គាល់ឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍បានពិណ៌នាអំពីកិច្ចនានាដែលបានស្នើសុំ ជាពិសេសការកំណត់អត្តសញ្ញាណទ្រព្យសម្បត្តិ និងទ្រព្យធនទាំងអស់របស់ជនត្រូវចោទ និងការពិនិត្យមើលប្រវត្តិនៃការទទួលបាននូវទ្រព្យសម្បត្តិ និងទ្រព្យធនទាំងអស់នោះ ថាជា "បុរេលក្ខខណ្ឌ" ចំពោះ "ការអនុវត្ត

00578864



ដោយប្រសិទ្ធភាព"[៥៥]។ ទោះបីជាបានពិពណ៌នាហើយក៏ដោយ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានផ្តល់នូវមូលដ្ឋានច្បាប់សម្រាប់ការទទួលយកវិធានការ "បុរេលក្ខខណ្ឌ" ឡើយ។ យ៉ាងច្រើនបំផុត ម្ចាស់បណ្តឹងឧទ្ធរណ៍គ្រាន់តែបានអះអាងថា ខ្លួនមានការព្រួយបារម្ភអំពីអ្វីដែលអាច ឬមិនអាចកើតឡើងនាពេលអនាគតប៉ុណ្ណោះ[៥៦]។

៣៤. ដើម្បីចាត់ទុកជាមោឃៈចំពោះដីកាដែលត្រូវបានជំទាស់ និងដើម្បីបង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតដឹកនាំកិច្ចស៊ើបសួរនៅក្នុងសំណើសុំ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះពិចារណាឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវធ្វើការបង្ហាញពីផលប្រយោជន៍ដែលត្រូវបានទទួលស្គាល់ ទោះបីវាជាផលប្រយោជន៍ជាយថាហេតុក៏ដោយ។ អង្គបុរេជំនុំជម្រះបានពិចារណាអំពីបញ្ហាថា តើម្ចាស់បណ្តឹងឧទ្ធរណ៍មានផលប្រយោជន៍ដែលត្រូវបានទទួលស្គាល់ដែលត្រូវធ្វើការការពារ តាមរយៈការចាត់ទុកជាមោឃៈចំពោះដីកាដែលត្រូវបានជំទាស់ដែរឬទេ។ ម្ចាស់បណ្តឹងឧទ្ធរណ៍អះអាងថា សំណូមពរនៅក្នុងសំណើសុំមានបំណងដោះស្រាយការព្រួយបារម្ភរបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិចំនួនពីរក្រុមៈ "...មិនពាក់ព័ន្ធតែទៅលើទ្រព្យសម្បត្តិដែលទទួលបានដោយខុសច្បាប់ដែលតុលាការអាចរឹបអូសបាននោះទេ ប៉ុន្តែថែមទាំងពាក់ព័ន្ធនឹងទ្រព្យសម្បត្តិទទួលបានដោយស្របច្បាប់ក្រោយថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដែលតុលាការមិនអាចរឹបអូសនៅឡើយ"ផងដែរ[៥៧]។ ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងថា "ការកំណត់អត្ត

---

[៥៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២៤។

[៥៦] នៅក្នុងបណ្តឹងឧទ្ធរណ៍ ម្ចាស់បណ្តឹងឧទ្ធរណ៍ខកខានមិនបានបរិយាយល្អិតល្អន់អំពីសនិទានភាពដែលមាននៅពីក្រោយការស្នើសុំការចាត់វិធានដែលចាំបាច់ជាមុនដើម្បីឱ្យមានការអនុវត្តឱ្យមានប្រសិទ្ធិភាព។ នៅក្នុងសំណើសុំ ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងថា "ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកសង្កេតការណ៍ឯករាជ្យទៅលើតុលាការ មានការព្រួយបារម្ភចំពោះអត្ថិភាពនៃសំណងខាងលើនេះនាពេលអនាគត។" សំណើ កថាខណ្ឌ១២។ នៅក្នុងផ្នែកបន្ទាប់មកទៀតនៃសំណើដើមបណ្តឹងឧទ្ធរណ៍សុំឱ្យសហចៅក្រមស៊ើបអង្កេត "[ចាត់]វិធានការធានាចំពោះទ្រព្យសម្បត្តិដែលត្រូវបានរកឃើញ ដើម្បីទុកសំរាប់សំណងដល់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលមានសេចក្តីជាស្ថាពររបស់តុលាការ" សំណើ កថាខណ្ឌ២៥។

[៥៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៧។



E.C.C.C. C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00578865



សញ្ញាណនូវទ្រព្យសម្បត្តិដែលទទួលបាននាពេលក្រោយៗមក អាចនឹងជួយសម្រួលដល់ការអនុវត្តដីកាសម្រេចលើសំណាងដូចគ្នា ប្រសិនបើមាន”[៥៨]។

៣៥. អង្គបុរេជំនុំជម្រះបកស្រាយផ្នែកទីមួយនៃប្រយោគទីមួយនៃអត្ថបទដកស្រង់ក្នុងកថាខណ្ឌមុននេះពាក់ព័ន្ធទៅនឹងក្រុមទ្រព្យសម្បត្តិទីមួយថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ជឿជាក់ថាតុលាការនេះមានអំណាចរឹបអូសទ្រព្យសម្បត្តិ ដែលទទួលបានដោយខុសច្បាប់នៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី។ អនុលោមតាមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ (“ច្បាប់ អ.វ.ត.ក”)[៥៩] អំណាចតែមួយគត់របស់តុលាការនេះ ក្នុងការរឹបអូសទ្រព្យសម្បត្តិដែលបានមកដោយខុសច្បាប់ ឬជាក់លាក់ជាងនេះទៀតដែលបានមកតាមរយៈការប្រព្រឹត្តិបទឧក្រិដ្ឋ គឺជាអង្គជំនុំជម្រះសាលាដំបូង។ មាត្រា ៣៩ ថ្មី នៃច្បាប់ ស្តីពីអង្គជំនុំជម្រះវិសាមញ្ញចែងថា:

> ជនទាំងឡាយដែលប្រព្រឹត្តបទឧក្រិដ្ឋណាមួយដូចមានចែងក្នុងមាត្រា ៣.៤.៥.៦.៧ និង ៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសឧក្រិដ្ឋដាក់ពន្ធនាគារពី ៥ឆ្នាំ រហូតដល់មួយជីវិត។ ក្រៅពីទោសដាក់ពន្ធនាគារ អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង អាចសម្រេចរឹបអូសទ្រព្យសម្បត្តិជាចលនវត្ថុ និងអចលនវត្ថុ និងលុយកាក់ដែលទទួលបានដោយខុសច្បាប់ ឬក៏បានដោយការប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម។ ទ្រព្យសម្បត្តិដែលរឹបអូសបាននេះត្រូវប្រគល់ជូនរដ្ឋ[៦០]។

៣៦. មាត្រា ៣៩ ថ្មី មិនផ្តល់អំណាច ឬអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះ ឬសហចៅក្រមស៊ើបអង្កេតរឹបអូសទ្រព្យសម្បត្តិដែលបានមកដោយខុសច្បាប់ ដោយសារមូលហេតុជាច្រើន។ ទីមួយ ការរឹបអូស ឬដកហូតទ្រព្យសម្បត្តិដែលបានមកដោយខុសច្បាប់ អាចបង្កើតបានជាផ្នែកមួយនៃដំណាក់កាលផ្តន្ទាទោសនៃកិច្ចដំណើរការនីតិវិធី ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចដូច្នេះ។ វាត្រូវមានសាលក្រមសម្រេចសេចក្តីមួយដែលនាំឱ្យមាន

---

[៥៨] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៧។

[៥៩] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ ដោយរួមទាំងវិសោធនកម្ម ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២00៤ (“ច្បាប់ អ.វ.ត.ក”)។

[៦០] ច្បាប់ អ.វ.ត.ក មាត្រា៣៩ ថ្មី។



E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00578866



ការផ្តន្ទាទោស មុនពេលអាចចេញបញ្ជាផ្តន្ទាទោសដែលអាចរួមមាន ការដាក់ពន្ធនាគារ និងការដកហូតទ្រព្យសម្បត្តិ។ ជាធម្មតា សមត្ថភាពនេះគឺស្ថិតនៅលើអ្នកជំនុំជម្រះអំពីអង្គហេតុដែលជាអង្គជំនុំជម្រះសាលាដំបូង មិនមែនជាអង្គបុរេជំនុំជម្រះនោះទេ។ ទីពីរ លក្ខខណ្ឌកំណត់អំពីទ្រព្យសម្បត្តិដែលរឹបអូសបានត្រូវប្រគល់ជូនរដ្ឋនោះ មានន័យថា ម្ចាស់បណ្តឹងឧទ្ធរណ៍ មិនមែនជាអ្នកកាន់កាប់លើផលប្រយោជន៍នៃទ្រព្យសម្បត្តិដែលបានមកដោយខុសច្បាប់តែម្នាក់ឯងនោះទេ។ នាពេលអនាគត រដ្ឋគឺជាអ្នកទទួលយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលបានមកដោយខុសច្បាប់ អចលនទ្រព្យ និងប្រាក់កាស ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងចេញដីការឹបអូស។ ដោយសារតែវិធានផ្ទៃក្នុង និងច្បាប់ អ.វ.ត.ក មិនផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីនូវសិទ្ធិតែមួយក្នុងការទទួលបាននូវទ្រព្យសម្បត្តិ និងផលនៃបទល្មើស ម្ចាស់បណ្តឹងឧទ្ធរណ៍មិនអាចទាមទារផលប្រយោជន៍ដែលត្រូវបានទទួលស្គាល់ ដែលគាំទ្រសំណើសុំបំពេញកិច្ចស៊ើបសួរឡើយ។ ការចាត់ទុកជាមោឃៈចំពោះដីកាដែលត្រូវបានជំទាស់ជាប្រយោជន៍ដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិដែលបានមកដោយខុសច្បាប់នឹង (i) អាចផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ជាងផលប្រយោជន៍របស់រដ្ឋដោយគ្មានយុត្តិកម្ម (ii) សន្មតទោសរបស់ជនត្រូវចោទ និង (iii) បុរេវិនិច្ឆ័យអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីផ្តល់សំណង និង/ឬ ចេញដីការឹបអូស នៅក្នុងករណីមានការផ្តន្ទាទោសបន្ទាប់ពីមានការជំនុំជម្រះលើការចោទប្រកាន់។

៣៧. គេបានកត់សម្គាល់ឃើញថា ភាពមិនអាចទាមទារបាន ឬស្នើសុំបានរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងនាមជាភាគីមួយដែលមានផលប្រយោជន៍នៅក្នុងចលនទ្រព្យ និងអចលនទ្រព្យទាំងឡាយដែលបានមកដោយខុសច្បាប់ មានភាពស្របទៅនឹងការបែងចែកអំណាច និងសិទ្ធិរវាងភាគីពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការនេះដែរ[៦១]។

---

៦១ សម្រាប់កិច្ចពិភាក្សាអំពីសមត្ថភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលជាច្រើននៃកិច្ចដំណើរការនីតិវិធី និងប្រសិទ្ធភាពនៃការកំណត់ព្រំដែននៃសមត្ថភាពរវាងភាគីនានា សូមមើល សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ សំណុំរឿងលេខ ០០១-១៨-០៧-២០០៧, *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន*

E.C.C.C * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00578867



បទបញ្ញត្តិស្តីពីការរឹបអូសចលនទ្រព្យ និងអចលនទ្រព្យដែលបានមកដោយខុសច្បាប់នៅក្នុងមាត្រា ៣៩ ថ្មី គឺជាផ្នែកមួយនៃការផ្តន្ទាទោសពិរុទ្ធជន។ មានតែសហព្រះរាជអាជ្ញាប៉ុណ្ណោះដែលអាចធ្វើសេចក្តីសន្និដ្ឋានដែលមានលក្ខណៈព្រហ្មទណ្ឌ[៦២]។ ដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រសហព្រះរាជអាជ្ញា នៅដំណាក់កាលផ្សេងទៀតនៃកិច្ចដំណើរការនីតិវិធី ជាពិសេស ដើម្បីជួយដល់ការស្វែងរកការពិតពាក់ព័ន្ធទៅនឹងការកំណត់សម្រេចអំពីពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធភាពរបស់ជនជាប់ចោទ។ ការរឹបអូសទ្រព្យសម្បត្តិដែលបានមកដោយខុសច្បាប់ ប្រសិនបើមាន គឺជាផ្នែកមួយនៃការផ្តន្ទាទោស និងមិនទាក់ទងទៅនឹងការសងសំណង ឬទៅនឹងតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ម្ចាស់បណ្តឹងឧទ្ធរណ៍ហាក់ដូចជាមិនយកចិត្តទុកដាក់លើលទ្ធភាពដែលអង្គជំនុំជម្រះសាលាដំបូង អាចចេញដីកាចាត់វិធានការព្រហ្មទណ្ឌមួយពាក់ព័ន្ធនឹងមូលនិធិដែលទទួលបានដោយខុសច្បាប់ ដោយត្រូវធ្វើការរឹបអូស ផ្ទុយទៅវិញម្ចាស់បណ្តឹងឧទ្ធរណ៍គ្រាន់តែពឹងផ្អែកនៅក្នុងសំណើសុំលើការសន្មតថា ការរឹបអូសទ្រព្យសម្បត្តិដែលបានមកដោយខុសច្បាប់អាចយកប្រើប្រាស់ធ្វើជាសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី[៦៣]។ ដោយសារតែវាមិនមែនដូច្នេះទេនោះ ម្ចាស់

---

អ.វ.ត.ក/អ.ជ.ស.ដ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ E72/3 (“សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី”)។

៦២ ចៅក្រមមួយរូបនៅអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា “មានតែសហព្រះរាជអាជ្ញាតែមួយគត់ដែលមានសមត្ថកិច្ចដើម្បីស្នើសុំការដាក់ទោស។ ជាការពិត មិនមែនដើមបណ្តឹងរដ្ឋប្បវេណីទេ ដែលត្រូវធ្វើការអត្ថាធិប្បាយណាមួយទាក់ទងនឹងអ្វីដែលខ្លួនអាចយល់ឃើញថា ជាទោសត្រឹមត្រូវ ឬមិនត្រឹមត្រូវ និងទាក់ទងនឹងបញ្ហាគតិយុត្តដែលអាចទាក់ទងនឹងទោស ជាឧទាហរណ៍ ករណីនៃការស្របបទល្មើស ឬករណីបូកបទល្មើសច្រើនបទ” មតិជំទាស់របស់ចៅក្រម Lavergne នៃអង្គជំនុំចម្រះសាលាដំបូង ចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ២៣។

៦៣ ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងថា ការចាត់វិធានការដើម្បីរក្សាទុកទ្រព្យសម្បត្តិសម្រាប់គោលបំណងនៃការជួសជុលសំណងតែមួយនោះ មានការពាក់ព័ន្ធប្រសិនបើគេរកឃើញថា “ទ្រព្យសម្បត្តិបានរកឃើញថាមានហើយទទួលបានដោយមធ្យោបាយខុសច្បាប់ ដែលស្ថិតនៅក្រោមយុត្តាធិការពេលវេលារបស់ អ.វ.ត.ក”។ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៣។ ដើមបណ្តឹងឧទ្ធរណ៍ថ្លែងបន្តទៀតថា “[នៅ]ពេលពិចារណាលើការអនុវត្ត ដោយសក្តិសមលើសំណងលក្ខខណ្ឌដំបូងនោះគឺត្រូវធ្វើអត្តសញ្ញាណកម្មលើទ្រព្យសម្បត្តិដើម្បីសម្រេចថាតើទ្រព្យសម្បត្តិ ទាំងនេះបានទទួលដោយខុសច្បាប់ឬយ៉ាងណា”។ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២៤។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE
E.C.C.C * C.E.T.C

បណ្តឹងឧទ្ធរណ៍ខ្វះមូលដ្ឋានក្នុងការធ្វើសំណើសុំ។ ហេតុនេះ បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបានទេផ្អែកតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។

៣៨. អង្គបុរេជំនុំជម្រះបកស្រាយផ្នែកទីពីរនៃប្រយោគទីមួយ នៃអត្ថបទដកស្រង់មកពីបណ្តឹងឧទ្ធរណ៍នៅក្នុងកថាខណ្ឌទី៣៤ខាងលើថា ម្ចាស់បណ្តឹងឧទ្ធរណ៍ជឿជាក់ថា អង្គជំនុំជម្រះនេះត្រូវចាត់ទុកជាមោឃៈចំពោះដីកាដែលត្រូវបានជំទាស់ ដើម្បីអនុញ្ញាតឱ្យមានការរឹបអូសយកទ្រព្យសម្បត្តិរបស់ជនត្រូវចោទទាំងអស់នោះ ដែលទទួលបានមកដោយស្របច្បាប់ក្រោយថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[៦៤]។ អង្គបុរេជំនុំជម្រះបានពិនិត្យលើសេចក្តីសន្និដ្ឋាននេះ ដើម្បីសម្រេចថាតើម្ចាស់បណ្តឹងឧទ្ធរណ៍មានផលប្រយោជន៍ដែលអាចពិចារណាបានដែរឬទេ បើទោះបីជាផលប្រយោជន៍ជាយថាហេតុក៏ដោយ នៅក្នុងទ្រព្យសម្បត្តិដែលទទួលបានមកដោយស្របច្បាប់របស់ជនត្រូវចោទ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការនេះ។

៣៩. ការផ្តល់សំណង ប្រសិនបើត្រូវបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង អាចរួមបញ្ចូលនូវការចំណាយផ្សេងៗទៀតដែលពិរុទ្ធជនត្រូវបង់។ ការអនុវត្តនេះអាចតម្រូវឱ្យមានការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ជននេះ។ ទ្រព្យសម្បត្តិដែលទទួលបានមកដោយខុសច្បាប់ ក៏ដូចជាដោយស្របច្បាប់ អាចយកមកប្រើប្រាស់ដើម្បីតម្រូវទៅតាមដីកាបង្គាប់ឱ្យសងសំណងដែលអាចមាន។ តុលាការនេះមិនត្រូវបានផ្តល់អំណាចឱ្យចាត់វិធានការ ដើម្បីរក្សាទុកទ្រព្យសម្បត្តិរបស់ជនត្រូវចោទណាម្នាក់ក្នុងគោលបំណងណាមួយឡើយ។ ច្បាប់ អ.វ.ត.ក វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបញ្ញត្តិច្បាប់រដ្ឋបាល ដែលមានជាធរមានមិនអនុញ្ញាតឱ្យតុលាការនេះបង្កក រឹបអូស ឬរក្សាទុកទ្រព្យសម្បត្តិទាំងឡាយនៅក្នុងបរិបទនៃការទាមទារសំណងនោះឡើយ។ អ.វ.ត.ក គ្មានយុត្តាធិការក្នុងការជួសជុល

[៦៤] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៧។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ទោះបីជាមានការយោងលើថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ នៅក្នុងបណ្តឹងឧទ្ធរណ៍ ក៏ដោយ ទ្រព្យសម្បត្តិរបស់ជនត្រូវចោទដែលបានមកដោយស្របច្បាប់មុនថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ក៏ស្ថិតក្រោមវិសាលភាពនៃសំណើសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ផងដែរ។

ព្យសនកម្ម ឬផ្តល់សំណងនោះទេ[៦៥]។ ដោយសារតុលាការនេះមិនអាចឆ្លើយតបទៅនឹងសំណើនេះបាន តុលាការនេះក៏មិនមានវិធាននីតិវិធីដែលប្រើប្រាស់ដោយតុលាការផ្សេងទៀត ដើម្បីចាត់វិធានការដែលមានគោលបំណងរក្សាទុកទ្រព្យសម្បត្តិទាំងឡាយ ដើម្បីធ្វើការបែងចែកនាពេលអនាគតដែលអាចមានបានដែរ។ ម្ចាស់បណ្តឹងឧទ្ធរណ៍មានកំហុសនៅក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ផ្អែកតាមការសន្មតថា អង្គបុរេជំនុំជម្រះអាចចេញដីកាបង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតដឹកនាំកិច្ចស៊ើបសួរដើម្បីសម្រួលដល់ការរឹបអូសទ្រព្យសម្បត្តិរបស់ជនត្រូវចោទនៅថ្ងៃក្រោយ។ លើសពីនេះទៀត ទោះបីជាតុលាការនេះមានសិទ្ធិអំណាចយល់ព្រមតាមការជួសជុលសំណងដែលបានស្នើសុំក៏ដោយ វាមិនស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការនេះទេ។ ម្ចាស់បណ្តឹងឧទ្ធរណ៍កំពុងស្នើសុំការជួសជុលសំណងដើម្បីសម្រួលដល់ការរក្សាទុកទ្រព្យសម្បត្តិនោះ។ ដោយសារតែតុលាការនេះមិនមានយុត្តាធិការក្នុងការអនុវត្តវិធានការដែលសំដៅដល់ការរក្សាទុកទ្រព្យសម្បត្តិ បណ្តឹងឧទ្ធរណ៍ក៏ត្រូវបានពិចារណាឃើញបន្ថែមទៀតថាមិនអាចទទួលយកបាន។

៤០. ពុំមានបទបញ្ញត្តិផ្សេងទៀតនៅក្នុងវិធានផ្ទៃក្នុង ឬនៅក្នុងច្បាប់ផ្សេងទៀតដែលមានជាធរមាននៅចំពោះមុខតុលាការនេះដែរ បើទោះជាបកស្រាយដោយទូលំទូលាយ ណែនាំថាដើមបណ្តឹងរដ្ឋប្បវេណីមានផលប្រយោជន៍ក្នុងទ្រព្យសម្បត្តិដែលបានមកដោយស្របច្បាប់និងខុសច្បាប់របស់ជនត្រូវចោទ ដែលអនុញ្ញាតឱ្យមានការរឹបអូស ឬចាត់វិធានការដើម្បីសម្រួលដល់ការរឹបអូស ធ្វើឡើងដោយអង្គបុរេជំនុំជម្រះ ឬសហចៅក្រមស៊ើបអង្កេតនោះឡើយ។

៤១. អង្គបុរេជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ត្រូវបានការពារគ្រប់គ្រាន់តាមរយៈក្របខណ្ឌច្បាប់ដែលមានស្រាប់។ អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន ២១ នៃវិធានផ្ទៃក្នុង មិនបានដាក់កាតព្វ

[៦៥] ដូចដែលបានកត់សម្គាល់ដោយសហចៅក្រមស៊ើបអង្កេត ពុំមានការចែងអំពីសិទ្ធិក្នុងការ[illegible]នូវសំណងផ្នែកហិរញ្ញវត្ថុដល់ជនរងគ្រោះម្នាក់ៗនោះឡើយ។ ដីកា កថាខណ្ឌ ២។

00578870



កិច្ចមកលើអង្គបុរេជំនុំជម្រះឲ្យធ្វើការបកស្រាយវិធានផ្ទៃក្នុង ដើម្បីឲ្យឃើញថា បណ្តឹងឧទ្ធរណ៍ត្រូវបានប្រកាសថាអាចទទួលយកនោះទេ។

អាស្រ័យមូលហេតុទាំងអស់ដែលបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះបានសម្រេចសេចក្តីដូចការប្រកាសនៅក្នុងសាលដីកា ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០។

យោងតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០

**អង្គបុរេជំនុំជម្រះ**

**Rowan DOWNING នៃ ប្រាក់ គឹមសាន** — **Rowan DOWNING ន៉ុយ ថុល Catherine MARCHI-UHEL ហួត វុទ្ធី ប្រាក់ គឹមសាន**